សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការជិះរថភ្លើងនៅពេលយប់ ឬក៏ការជិះរថភ្លើងរាត្រី អញ្ចឹងពេលយប់ឬក៏ពេលរាត្រី យើងអាចហៅបានពីរ យើងអាចហៅបានថាពេលយប់ ឬក៏ហៅថាពេលរាត្រី

អញ្ចឹងនៅក្នុងរូបភាពទី ១ យើងឃើញមានស្ថានីយរថភ្លើងមួយ ដែលស្ថានីយរថភ្លើងនេះ គឺយើងឃើញមានទង់ជាតិមួយនៅខាងលើ ដែលដំបូលស្ថានីយរថភ្លើង គឺមានរាងកោង ហើយមានដំបូលចំនួនបី ហើយនៅខាងមុខស្ថានីយរថភ្លើងនេះ គឺយើងមាន ឃើញនាឡិកាចំនួនមួយផងដែរ ដោយស្ថានីយរថភ្លើងនេះ គឺប្រហែលជាស្ថានីយរថភ្លើងដែលនៅក្នុងប្រទេសថៃ ឬក៏ប្រទេសសិង្ហបុរី ឬក៏ប្រទេសម៉ាឡេស៊ីជាដើម ព្រោះថានៅក្នុងប្រទេសកម្ពុជា គឺយើងមានស្ថានីយរថភ្លើងដែរ ក៏ប៉ុន្តែស្ថានីយរថភ្លើងគឺចាស់ អញ្ចឹងយើងអត់ប្រើប្រាស់ទេ គឺយើងប្រើប្រាស់សម្រាប់តែដឹកអីវ៉ាន់ ឬក៏ដឹកទំនិញតែប៉ុណ្ណោះ ដោយយើងអត់ប្រើប្រាស់សម្រាប់ក្នុងការដឹកជញ្ជូនមនុស្សនោះទេ ព្រោះតែស្ថានីយរថភ្លើងរបស់យើងចាស់ ហើយយើងមានតែរថភ្លើងចាស់ៗ ដែលសល់ពីជំនាន់ដើម អញ្ចឹងគឺយើងអត់មានរថភ្លើងថ្មីសម្រាប់ដឹកអ្នកដំណើរនោះទេ អញ្ចឹងយើងមើលឃើញក្នុងរូបភាពទី ១ នេះ គឺជាស្ថានីយរថភ្លើង ដែលប្រហែលជាស្ថានីយនៅក្នុងប្រទេសថៃ ឬក៏ប្រទេសសិង្ហបុរីជាដើម ដោយយើងឃើញនៅជុំវិញស្ថានីយរថភ្លើង យើងឃើញមានដើមឈើតូចធំជាច្រើនដុះជុំវិញនោះ ដោយយើងឃើញមើលទៅមានពណ៌បៃតង គឺបានន័យថាស្ថានីយរថភ្លើងនេះ គឺនៅជាយក្រុង អញ្ចឹងនៅតំបន់ជាយក្រុងគឺសម្បូររថភ្លើងណាស់ ដូច្នេះហើយយើងឃើញនៅក្នុងរូបភាពនេះ គឺមានដើមឈើជាច្រើន ដែលដុះនៅតាមជាយក្រុង។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា មានមនុស្សប្រុសស្រី និងក្មេងចាស់ជាច្រើន កំពុងតែឈរតម្រង់ជួរគ្នា ដើម្បីទិញសំបុត្ររថភ្លើង អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ២ នេះ គឺមានមនុស្សឈរតម្រង់ជួរគ្នាជាច្រើន ដែលនៅ នៅអ្នកដែលឈរនៅខាងមុខគេ គឺអ្នកដែលឈរនៅជិតកន្លែងលក់សំបុត្រ គឺគាត់ជាមនុស្សប្រុស ដែលគាត់មានសក់ខ្លី គាត់ពាក់អាវដៃខ្លីពណ៌លឿង និងខោជើងវែងពណ៌ខ្មៅ នៅក្បែរខ្លួនគាត់ គឺមានកាបូបពណ៌ទឹកក្រូចចំនួនមួយ ដែលកាបូប ឬក៏កាតាបនោះគឺជាសម្រាប់ដាក់អីវ៉ាន់របស់គាត់ អញ្ចឹងបានន័យថាគាត់ធ្វើដំណើរផ្លូវឆ្ងាយ នៅពេលដែលយើងធ្វើដំណើរផ្លូវឆ្ងាយ យើងត្រូវមានកាបូប ឬក៏កាតាប ឬក៏វ៉ាលិស សម្រាប់ដាក់ខោអាវ ឬក៏ដាក់សម្ភារៈផ្សេងៗ ដើម្បីប្រើប្រាស់ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញបុរសម្នាក់នោះ គាត់មានវ៉ាលិសពណ៌ទឹកក្រូចមួយ អញ្ចឹងគាត់ដាក់ខោអាវនិងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់គាត់ នៅក្នុងវ៉ាលិសពណ៌ទឹកក្រូចនោះ ព្រោះគាត់ត្រូវធ្វើដំណើរតាមរថភ្លើងទៅឆ្ងាយ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតអ្នកដែលឈរនៅកណ្ដាល អ្នកដែលឈរនៅកណ្ដាល គឺមានក្មេងស្រីម្នាក់ និងបុរសម្នាក់ ដែលបុរសម្នាក់នោះ គឺជាឪពុករបស់ក្មេងស្រី ដោយយើងឃើញបុរសម្នាក់នោះ គាត់ឈរជាប់នឹង[ក្មេង]កូនស្រីរបស់គាត់តែម្ដង ព្រោះខ្លាចកូនគាត់វង្វេង ដោយសារតែមនុស្សនៅក្នុងស្ថានីយរថភ្លើងគឺមានច្រើន ដូច្នេះប្រសិនបើគាត់ឲ្យកូនគាត់ដើរឆ្ងាយពីគាត់ គាត់អាចនឹងវង្វេងគ្នា គាត់អាចវង្វេងបាត់កូនស្រីរបស់គាត់ ដូច្នេះគាត់មិនអនុញ្ញាតឲ្យកូនស្រីរបស់គាត់ដើរឆ្ងាយនោះទេ ដោយយើងឃើញកូនស្រីម្នាក់នោះ គាត់ឃើញ យើងឃើញគាត់ពាក់អាវពណ៌ទឹកក្រូចដៃវែង ហើយចងសក់ទីទុយ ក្មេងស្រីនោះ គាត់ស្លៀកខោពណ៌សជើងវែង និងពាក់ស្បែកជើងប៉ាតា គាត់ឈរជាប់នឹងឪពុករបស់គាត់ ដែលមានពាក់អាវពណ៌សដៃខ្លី ខោជើងវែងពណ៌ស ហើយមានវ៉ាលិសពណ៌បៃតងនៅក្បែរគាត់ផងដែរ អញ្ចឹងបុរសដែលជាឪពុកនោះ គាត់មានវ៉ាលិសពណ៌បៃតងផងដែរ ដោយសារតែគាត់ត្រូវធ្វើដំណើរផ្លូវឆ្ងាយដូចគ្នា អញ្ចឹងគាត់ត្រូវការតែ ត្រូវការវ៉ាលិសមួយសម្រាប់ដាក់សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន មានដូចជាខោអាវ សាប៊ូកក់សក់ ខោ ស្បែកជើងជាដើម ដោយគាត់ដាក់នៅក្នុងវ៉ាលិសពណ៌បៃតងរបស់គាត់នោះ អញ្ចឹងគាត់កំពុងតែឈរតម្រង់ជួរដើម្បីទិញសំបុត្ររថភ្លើង ដែលយើងឃើញនៅខាងក្រោយបុរសដែលពាក់អាវសនោះ យើងឃើញមានបុរសម្នាក់ទៀត ដោយគាត់មានវយប្រហែលជា ២០ ឆ្នាំ អញ្ចឹងគាត់ពាក់អាវពណ៌ស្វាយដៃខ្លី ខោជើងវែងពណ៌ស យើងឃើញគាត់ស្ពាយកាតាបមួយផងដែរ ដោយពេលខ្លះយើងអត់ចាំបាច់ប្រើវ៉ាលិសនោះទេ យើងគ្រាន់តែប្រើកាតាបតូចមួយ ដើម្បីល្មមសម្រាប់ដាក់សម្ភារៈផ្ទាល់ខ្លួនយើងក៏បានដែរ នៅពេលដែលយើងធ្វើដំណើរ អញ្ចឹងប្រសិនបើយើងទៅម្នាក់ឯង យើងអត់មានគ្នាច្រើន យើងអាចប្រើកាតាប ដើម្បីដាក់ខោអាវបន្តិចបន្តួចរបស់យើង ដូចជាក់ស្ដែងនៅក្នុងរូបភាពទី ២ នេះ គឺបុរសដែលពាក់អាវពណ៌ស្វាយ គាត់ស្ពាយកាតាបមួយ ដៃរបស់គាត់គឺច្រត់ទៅចង្កេះ គឺជ្រែងហោប៉ៅ អញ្ចឹងគាត់យកដៃរបស់គាត់ជ្រែងហោប៉ៅ ដោយដៃខាងស្ដាំរបស់គាត់ គឺលូកចូលក្នុងហោប៉ៅ ហើយដៃខាងឆ្វេងរបស់គាត់គឺទម្លាក់ចុះ អញ្ចឹងយើងហៅថាគាត់កំពុងតែឈរជ្រែងហោប៉ៅ អញ្ចឹងពួកគាត់ទាំងអស់គ្នា គឺកំពុងតែតម្រង់ជួរគ្នា ដើម្បីទិញសំបុត្ររថភ្លើង។

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញបុរសម្នាក់ដែលពាក់អាវពណ៌លឿង ដៃខ្លីនោះ គាត់កំពុងតែប្រាប់ទៅអ្នកលក់សំបុត្ររថភ្លើង ដើម្បីទិញសំបុត្ររថភ្លើងមួយសន្លឹក ដោយគាត់ប្រាប់អំពីកន្លែងចេញដំណើរ កន្លែងទៅដល់របស់គាត់ដែលគាត់ចង់ទៅ អញ្ចឹងគាត់ប្រាប់អំពីគោលដៅរបស់គាត់ ដែលគាត់ចង់ទៅ ដូច្នេះហើយយើង ជាទូទៅគឺរថភ្លើងគឺមានច្រើនខ្សែ ហើយមានច្រើនប្រភេទ បានន័យថារថភ្លើងមានច្រើនខ្សែ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូចជាពេលព្រឹក ខ្សែរត់ពេលថ្ងៃ ខ្សែរត់ពេលយប់ជាដើម អញ្ចឹងអ្នកលក់នឹងសួរទៅបុរសម្នាក់នោះថា
តើគាត់ចង់បានខ្សែមួយណា ខ្សែយប់ ខ្សែព្រឹក ឬក៏ខ្សែថ្ងៃ
ហើយរថភ្លើងគឺមានកៅអីផ្សេងៗគ្នាផងដែរ យើងហៅថាកៅអីវីអាយភី និងកៅអីធម្មតា
អញ្ចឹងប្រសិនបើគាត់ជាអ្នកមាន គឺគាត់ចង់ទិញ គាត់ចង់អង្គុយកៅអីដែលមានផាសុខភាព
គាត់អាចទិញយកកៅអីវីអាយភី ប៉ុន្តែកៅអីវីអាយភីគឺថ្លៃជាងកៅអីធម្មតា
ដោយសារតែកៅអីវីអាយភីគឺមានការបម្រើនិងការយកចិត្តទុកដាក់ច្រើនជាងកៅអីធម្មតា
ហើយកៅអីធម្មតាគឺមានតម្លៃថោក អញ្ចឹងជាទូទៅប្រសិនបើយើងអត់សូវមានលុយ
យើងទិញកៅអីធម្មតា ប៉ុន្តែសម្រាប់អ្នកមាន គេប្រើប្រាស់ ឬក៏គេអង្គុយកៅអីវីអាយភី
ហើយជាទូទៅរថភ្លើង ជាធម្មតាគឺតែងតែមានកៅអីអង្គុយពីរទៅបីជួរ ដូច្នេះអ្នកលក់នឹងសួរយើងថា
តើយើងចង់បានកៅអីជាប់បង្អួច ឬក៏កៅអីជាប់ផ្លូវដើរ អញ្ចឹងប្រសិនបើយើងចូលចិត្តមើលទេសភាព
យើងអាចអង្គុយកៅអីជាប់មាត់បង្អួច ប៉ុន្តែប្រសិនបើយើងអត់ចូលចិត្តទេសភាពទេ
យើងអាចអង្គុយជាប់ផ្លូវដើរបាន ដូច្នេះអ្នកលក់នឹងសួរទៅកាន់យើង
នៅពេលដែលយើងទិញសំបុត្ររថភ្លើង អញ្ចឹងហើយបុរសម្នាក់នោះ
គាត់ក៏បានប្រាប់ទៅដល់អ្នកលក់ថាទិញសំបុត្រមួយច្បាប់ ឬក៏មួយសន្លឹក ដោយយកកៅអីជាប់បង្អួច
ហើយមានគ្រែគេងផងដែរ ព្រោះថារថភ្លើងពេលយប់ អញ្ចឹងរថភ្លើងពេលយប់ គឺមាន
តែងតែមានគ្រែគេងមួយសម្រាប់អ្នកដំណើរគេងពេលយប់ ដូច្នេះប្រសិនបើគាត់យកគ្រែគេង
គឺគេនឹងឲ្យសំបុត្រដែលមានគ្រែគេង ក៏ប៉ុន្តែប្រសិនបើគាត់អត់ចង់គេងទេ
គឺគេអត់ឲ្យសំបុត្រគ្រែគេងនោះទេ ព្រោះថាគ្រែគេងនៅលើរថភ្លើង គឺមានកំណត់ គឺមានចំនួនកំណត់
អញ្ចឹងគេឲ្យតែអ្នកចង់បានចង់គេងតែប៉ុណ្ណោះ ប្រសិនបើយើងអត់ចង់គេង គេនឹងអត់ឲ្យទេ។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញបុរសម្នាក់នោះ
គាត់ក៏បានទិញបានសំបុត្ររថភ្លើងមួយសន្លឹក ដែលនៅលើសំបុត្ររថភ្លើង
យើងឃើញសរសេរពីទីក្រុងបាងកកទៅដល់ទីក្រុងកូឡាឡាំពួរ
អញ្ចឹងយើងដឹងហើយថាទីក្រុងបាងកកគឺជាទីក្រុងរបស់ប្រទេសថៃ អញ្ចឹងប្រទេសថៃ
រាជធានីរបស់ប្រទេសថៃ គឺមានឈ្មោះថាបាងកក ចំណែកឯកូឡាឡាំពួរ
គឺជាទីក្រុងរបស់ប្រទេសម៉ាឡេស៊ី អញ្ចឹងរាជធានីរបស់កូឡាឡាំពួរ គឺយើងហៅថា ម៉ាឡេស៊ី
រាជធានីរបស់ប្រទេសម៉ាឡេស៊ី គឺយើងហៅថាកូឡាឡាំពួរ
អញ្ចឹងទីក្រុងបាងកកនិងទីក្រុងកូឡាឡាំពួរ គឺនៅក្នុងប្រទេសពីរផ្សេងគ្នា
ប៉ុន្តែប្រទេសទាំងពីរនៅក្នុងតំបន់អាស៊ានដូចគ្នា អញ្ចឹងយើងដឹងថាអាស៊ាន គឺជាតំបន់មួយ ដែលមាន
១០ ប្រទេស ដូចជា កម្ពុជា ប្រទេសថៃ ប្រទេសឡាវ ប្រទេសមីយ៉ាន់ម៉ា ប្រទេសវៀតណាម
ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ប្រទេសសិង្ហបុរី ជាដើម។ អញ្ចឹងប្រទេសទាំងដប់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺនៅក្នុងតំបន់អាស៊ានតែមួយ អញ្ចឹងក្នុងការធ្វើដំណើរពីទីក្រុងបាងកកទៅទីក្រុងកូឡាឡាំពួរ
យើងអាចជិះរថភ្លើងក៏បាន យើងអាចជិះយន្តហោះក៏បានដែរ ដោយសារតែនៅជិតគ្នា
អញ្ចឹងនៅក្នុងរូបភាពនេះ គឺបុរសម្នាក់នោះ គាត់បានទៅ ទៅទីក្រុងកូឡាឡាំពួរ
ដោយចាកចេញពីទីក្រុងបាងកកនៃប្រទេសថៃ ទៅដល់ទីក្រុងកូឡាឡាំពួរនៃប្រទេសម៉ាឡេស៊ី
ដោយប្រើរថភ្លើង អញ្ចឹងនៅលើសំបុត្រយើងឃើញថា គឺជាសំបុត្ររថភ្លើង
ដែលយើងឃើញមានរូបភាពរថភ្លើងកំពុងតែសណ្ដោងរ៉ឺម៉ក អញ្ចឹងរថភ្លើងគឺមានច្រើនទូ
គឺមានក្បាលរថភ្លើង មានខ្លួនរថភ្លើងជាច្រើន ហើយនៅក្បែររូបភាពរថភ្លើងនោះ
គឺឃើញមានគ្រែគេង អញ្ចឹងបានន័យថាសំបុត្ររថភ្លើងរបស់គាត់ គឺជាសំបុត្រដែលមានគ្រែគេង
អញ្ចឹងបានន័យថាគាត់អាចអង្គុយនៅកន្លែងដែលមានគ្រែគេងបាន
អញ្ចឹងនៅពេលដែលគាត់ងងុយគេង គាត់អាចគេងលើគ្រែបាន
ហើយនៅពេលដែលគាត់អត់ងងុយគេងទេ គាត់អាចអង្គុយបាននៅលើរថភ្លើងនោះ។

បន្ទាប់មកទៀតរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ បន្ទាប់ពីគាត់ទទួលបានសំបុត្ររថភ្លើងរួចរាល់ហើយ
បុរសម្នាក់នោះ គាត់ក៏បានដើរមកកាន់កន្លែងចេញដំណើរ អញ្ចឹងនៅក្នុងស្ថានីយរថភ្លើងនោះគឺធំ
គឺយើងឃើញថាមានស្ថានីយរថភ្លើង ឬក៏កន្លែងចេញដំណើរចំនួនជាច្រើន ដូចជាគេបានដាក់លេខ
ដែលយើងឃើញនៅក្នុងរូបភាពនេះគឺមានចំនួនបី អញ្ចឹងអ្នកដំណើរដែលនៅទៅកន្លែងផ្សេង
មិនមែនទៅទីក្រុងកូឡាឡាំពួរ គឺធ្វើដំណើរទៅច្រកចេញដំណើរកន្លែងផ្សេង ដែលមានលេខមួយ
លេខពីរ និងលេខបីជាដើម អញ្ចឹងដោយសារតែច្រកលេខបី
គឺជាច្រករថភ្លើងសម្រាប់ទៅប្រទេសកូឡាឡាំពួរ ឬក៏ប្រទេសម៉ាឡេស៊ី អញ្ចឹងបុរសម្នាក់នោះ
គាត់ក៏បានដើរមកកាន់ច្រកចេញដំណើរលេខបី
ដោយយើងឃើញមានអ្នកដំណើរប្រុសស្រីជាច្រើនទៀត កំពុងតែឈរចាំរថភ្លើង
ទៅតាមជើងចេញដំណើររបស់គេ ដោយសារគេទៅកន្លែងផ្សេង ដូច្នេះគេនៅចាំច្រកទីមួយ
ច្រកទីពីរជាដើម ហើយគេមិនមកចាំច្រកទីបីទេ
ដោយសារតែច្រកទីបីគឺជាច្រកចេញដំណើររបស់រថភ្លើងសម្រាប់ទៅប្រទេសម៉ាឡេស៊ី
នៅក្នុងទីក្រុងកូឡាឡាំពួរ អញ្ចឹងបុរសម្នាក់នោះ គាត់បានដើរមកកាន់ច្រកចេញដំណើរទីបី
ដើម្បីទៅកាន់ប្រទេសម៉ាឡេស៊ី ឬក៏ទៅទីក្រុងកូឡាឡាំពួរ។

បន្ទាប់មកទៀតរូបភាពទី ៦ រូបភាពទី ៦ បន្ទាប់ពីគាត់មកដល់ច្រកចេញដំណើរហើយ
បន្តិចក្រោយមក រថភ្លើងក៏មកដល់ អញ្ចឹងរថភ្លើងបានបើកទ្វារ នៅក្នុងរូបភាពទី ៦ នេះ
រថភ្លើងបានបើកទ្វារ បន្ទាប់មកបុរសម្នាក់នោះ គាត់ក៏បានដើរចូលទៅក្នុងរថភ្លើងនោះ
ដោយយើងឃើញគាត់ ដៃម្ខាងរបស់គាត់កាន់ទ្វារដើម្បីតោងឡើង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងបានន័យថាគាត់ត្រូវឈានឡើងខ្ពស់ ដូច្នេះគាត់ត្រូវតោងដើម្បីទប់លំនឹងរបស់គាត់កុំឲ្យដួល ព្រោះថាប្រសិនបើយើងដួលនៅស្ថានីយរថភ្លើង គឺអាចមានគ្រោះថ្នាក់ ជាពិសេសនៅលើផ្លូវរថភ្លើង ប្រសិនបើយើងអាចដួល វាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់ដល់ជីវិតបាន ដូច្នេះយើងត្រូវទប់ខ្លួនដោយតោងទ្វារកុំឲ្យដួល ដោយយើងឃើញដៃម្ខាងទៀតរបស់គាត់ កំពុងតែអូសវ៉ាលិស អញ្ចឹងវ៉ាលិសគាត់ គឺជាវ៉ាលិសអូស ឬក៏ជាវ៉ាលិសមានកង់រុញ ដូច្នេះគាត់ពុំចាំបាច់យួរទេ គាត់គ្រាន់តែអូសជាការស្រេច អញ្ចឹងគាត់បានចាប់បង្កាន់ដៃរបស់វ៉ាលិស រួចហើយអូសវ៉ាលិសទៅតាមខ្លួនរបស់គាត់ ដោយគាត់មិនចំណាយកម្លាំង ដើម្បីលើកវ៉ាលិសឡើងនោះទេ អញ្ចឹងនៅក្នុងរូបភាពទី ៦ នេះ គឺគាត់កំពុងតែអូសវ៉ាលិសឡើងលើរថភ្លើង ដើម្បីចេញដំណើរទៅកាន់ទីក្រុងកូឡាឡាំពួរ នៃប្រទេសម៉ាឡេស៊ី។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា បន្ទាប់ពីគាត់ឡើងដល់រថភ្លើងហើយ យើងឃើញថា គាត់ក៏បានមកអង្គុយនៅលើកៅអីរបស់គាត់ ដោយគាត់បានទិញសំបុត្រ អញ្ចឹងសំបុត្ររបស់គាត់ គឺជាសំបុត្រអង្គុយដែលនៅក្បែរបង្អួច ព្រោះគាត់ចូលចិត្តមើលទេសភាព ដូច្នេះហើយគាត់ក៏បានទិញកៅអី ឬក៏ទិញសំបុត្ររថភ្លើង ដែលអង្គុយនៅជិតមាត់បង្អួច អញ្ចឹងយើង នៅក្នុងរូបភាពទី ៧ នេះ យើងឃើញបុរសម្នាក់នោះ គាត់ក៏បានអង្គុយ ហើយគាត់បានញញឹម និងធ្វើទឹកមុខសប្បាយរីករាយ ដោយសារតែគាត់បានអង្គុយជិតបង្អួច ដែលគាត់អាចមើលទេសភាពទៅខាងក្រៅឃើញ គឺយើងឃើញមានពពកពណ៌សជាច្រើន កំពុងតែរសាត់នៅលើមេឃ អញ្ចឹងថ្ងៃនេះមេឃស្រឡះ គឺអត់មានភ្លៀងទេ អញ្ចឹងមាន យើងឃើញមានពពកពណ៌សជាច្រើនកំពុងតែរសាត់នៅលើមេឃ ហើយយើងឃើញមានទេសភាព មានដើមឈើពណ៌បៃតងជាច្រើន ដែលកំពុងតែដុះនៅលើដី អញ្ចឹងនៅទីនេះ យើងឃើញមានផ្ទះចំនួនមួយ គឺជាផ្ទះប្រជាជន ដូច្នេះយើងឃើញថានៅជាយក្រុង គឺសម្បូរទៅដោយព្រៃឈើពណ៌បៃតង អញ្ចឹងហើយគឺមានទេសភាពស្រស់ស្អាត ដូច្នេះប្រសិនបើយើងជិះរថភ្លើង គឺយើងជិះ នៅជិតបង្អួចទើបយើងអាចមើលឃើញទេសភាពស្រស់ស្អាត នៅតាមដងផ្លូវបាន ជាក់ស្ដែងដូចបុរសម្នាក់នេះ គាត់បានយកកៅអីជាប់មាត់បង្អួច ដើម្បីមើលទេសភាពនៅតាមដងផ្លូវ ដែលថាព្រោះគាត់ចូលចិត្តមើលទេសភាពតាមដងផ្លូវ ដោយមានរុក្ខជាតិ ឬក៏ធម្មជាតិពណ៌បៃតង។

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា បន្ទាប់ពីគាត់ឡើងដល់រថភ្លើងមួយសន្ទុះក្រោយមក គឺមានបុរសម្នាក់មកឆែកសំបុត្រ អញ្ចឹងជាទូទៅនៅពេលដែលយើងជិះរថភ្លើង ឬក៏យើងជិះឡានក្រុង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅពេលដែលឡានរៀបចេញដំណើរ ឬក៏រថភ្លើងជិតចេញដំណើរ គឺតែងតែមានមនុស្សម្នាក់ ដើម្បីមកពិនិត្យសំបុត្ររបស់យើងថាតើយើងបានទិញសំបុត្រហើយឬនៅ ឬក៏តើយើងឡើងរថភ្លើងត្រឹមត្រូវដែរឬទេ ព្រោះខ្លះ ពេលខ្លះប្រសិនបើគេអត់ឡើងមកត្រួតសំបុត្រទេ ពេលខ្លះមានអ្នកខ្លះ គាត់អត់ទិញសំបុត្ររថភ្លើងទេ គឺគាត់បន្លំ គាត់ឡើងជិះដោយមិនទិញសំបុត្ររថភ្លើង ដូច្នេះគេមិនអនុញ្ញាតឲ្យជិះរថភ្លើង ដោយមិនមានសំបុត្រនោះទេ ហើយពេលខ្លះមានអតិថិជនខ្លះទៀត ឬក៏មានអ្នកដំណើរខ្លះទៀត គាត់ច្រឡំជើងរថភ្លើង បានន័យថាប្រសិនបើគាត់ទៅកន្លែងផ្សេង គាត់មិនអាចឡើងមករថភ្លើងទៅកូឡាឡាំពួរទេ អញ្ចឹងនៅពេលដែលគេពិនិត្យឃើញសំបុត្រនោះខុស គេនឹងឲ្យអ្នកដំណើរនោះ ចេញពីរថភ្លើងនោះ ដើម្បីទៅរករថភ្លើងផ្សេងទៀត ដែលត្រូវទៅគោលដៅរបស់គេ អញ្ចឹងហើយគេតែងតែមានអ្នកពិនិត្យសំបុត្រមើលថា តើអ្នកដំណើរទាំងអស់មានសំបុត្រត្រឹមត្រូវដែរឬទេ ដើម្បីឡើងជិះរថភ្លើងមួយនោះ ប្រសិនបើមិនត្រឹមត្រូវទេ គេនឹងឲ្យស្វែងរករថភ្លើងផ្សេងទៀត ដែលត្រូវទៅដល់គោលដៅរបស់គេ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញបុរសដែលពាក់អាវលឿង គាត់បានហុចសំបុត្រទៅឲ្យបុរសម្នាក់ ដែលពាក់អាវពណ៌បៃតងដៃវែង អញ្ចឹងបុរសម្នាក់នោះ គាត់គឺជាអ្នកត្រួតពិនិត្យសំបុត្រ អញ្ចឹងយើងឃើញថា គាត់បានយកសំបុត្រនោះ ទៅហែកកន្ទុយសំបុត្រចេញ ព្រោះសំបុត្រតែងតែមានពីរផ្នែក អញ្ចឹងសំបុត្ររថភ្លើងមានពីរផ្នែក អញ្ចឹងគេយកកន្ទុយសំបុត្រ អញ្ចឹងអ្នកត្រួតពិនិត្យសំបុត្ររថភ្លើង គាត់ហែកយកកន្ទុយសំបុត្រ ដោយយកសំបុត្រវែងឲ្យទៅបុរសម្នាក់នោះវិញ ដោយបុរស អ្នកត្រួតពិនិត្យសំបុត្រ គាត់គ្រាន់តែយកកន្ទុយសំបុត្រតែប៉ុណ្ណោះ ដើម្បីយកទៅត្រួតពិនិត្យ។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ យើងឃើញបុរសម្នាក់នោះ គាត់អង្គុយមើលទៅក្មេងប្រុសម្នាក់ ដែលមានអាយុប្រហែល ១៨ ឆ្នាំ គាត់កំពុងតែអំពាវនាវលក់ចំណីអាហារនៅលើរថភ្លើង អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា មានក្មេងប្រុសម្នាក់អាយុ ១៨ ឆ្នាំ គាត់ពាក់អាវសដៃខ្លី ខោជើងវែងពណ៌ស ហើយគាត់កំពុងតែស្ពាយនូវចំណីជាច្រើន មានដូចជានំ មានដូចជាភេសជ្ជៈជាដើម ដែលគាត់ដាក់ភេសជ្ជៈ ឬក៏នំទាំងនោះនៅលើថាសមួយ ហើយគាត់ចងខ្សែថាសនោះ ទៅនឹងខ្លួនរបស់គាត់ អញ្ចឹងគាត់ដើរស្ពាយថាសនោះ ហើយដៃម្ខាងរបស់គាត់លើកចំណីនោះឡើង ឬក៏លើកនំនោះឡើង ដើម្បីអំពាវនាវលក់ អញ្ចឹងគាត់ដើរស្រែកសួរទៅដល់អ្នកដំណើរទាំងអស់ ថាតើចង់ញ៉ាំនំ ឬក៏ចង់ទិញនំរបស់គាត់ដែរឬទេ អញ្ចឹងប្រសិនបើទិញ គាត់អាចលក់ឲ្យអ្នកដំណើរទាំងអស់នោះបាន ដោយគាត់ដើរបណ្ដើរ លើកនំគាត់បណ្ដើរ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយអំពាវនាវលក់បណ្ដើរ អញ្ចឹងគាត់ដើរឆ្លងពីកន្លែងមួយទៅកន្លែងមួយ ពីទូរថភ្លើងមួយទៅទូរថភ្លើងមួយ ដើម្បីអំពាវនាវលក់នំរបស់គាត់នៅលើរថភ្លើង ចំណែកឯបុរសដែលពាក់អាវលឿង នៅពេលដែលឮគេអំពាវនាវលក់ចំណីអាហារ គាត់ក៏បានងាកមើលផងដែរ ក៏ប៉ុន្តែគាត់អត់បានទិញនោះទេ គឺគាត់គ្រាន់តែងាកមើលអ្នកលក់តែប៉ុណ្ណោះ។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ នៅពេលដែលគាត់ជិះមួយសន្ទុះ ឬក៏ជិះយ៉ាងយូរម៉ោង ឬក៏ជិះយ៉ាងច្រើនម៉ោងក្រោយមក វាក៏ជាពេលយប់ អញ្ចឹងគឺនៅពេលយប់ បានន័យថាពីទីក្រុងបាងកកទៅទីក្រុងកូឡាឡាំពួរគឺឆ្ងាយគួរសម ដូច្នេះហើយទើបយើងជិះពីពេលថ្ងៃ រហូតដល់ពេលយប់ មិនទាន់ទៅដល់ទេ អញ្ចឹងដោយសារតែបុរសម្នាក់នោះ គាត់បានទិញកៅអីដែលមានគ្រែគេង ដូច្នេះនៅពេលដែលយប់ គាត់អាចលាកៅអីរបស់គាត់ ធ្វើជាគ្រែគេងបាន អញ្ចឹងកៅអីដែលគាត់អង្គុយ គាត់អាចលាតទៅជាពូក ដើម្បីគេងនៅពេលយប់ ដែលនៅក្នុងរូបភាពនេះ យើងឃើញបុរសដែលពាក់អាវលឿងនោះ គាត់កំពុងតែលាតកៅអីរបស់គាត់ឲ្យទៅជាគ្រែមួយដើម្បីគេង អញ្ចឹងយើងឃើញនៅខាងក្រៅគឺមានព្រះចន្ទ ហើយមានផ្កាយជាច្រើនកំពុងតែរះ អញ្ចឹងបានន័យថាវាជាពេលយប់ ដូច្នេះយើងអត់អាចមើលឃើញទេសភាពពណ៌បៃតងនោះទេ គឺអ្វីៗទាំងអស់ គឺនឹងប្រែទៅជាពណ៌ខ្មៅ ដោយសារតែផ្លូវរថភ្លើង ជាទូទៅគឺធ្វើនៅតាមទីជនបទ ដូច្នេះអត់មានភ្លើងអគ្គិសនីបំភ្លឺផ្លូវទេ អញ្ចឹងនៅពេលយប់គឺតែងតែងងឹត ដោយសារអត់មានភ្លើងអគ្គិសនី អញ្ចឹងហើយយើងអត់អាចមើលទេសភាពឃើញទេ គឺយើងឃើញតែមានតែពណ៌ខ្មៅតែប៉ុណ្ណោះ ហើយយើងឃើញនៅកន្លែងគេងរបស់បុរសម្នាក់នោះ គឺយើងឃើញមានវាំងននពីរ អញ្ចឹងបានន័យថានៅពេលដែលយើងអង្គុយ យើងអត់ចាំបាច់បិទវាំងននទេ ក៏ប៉ុន្តែប្រសិនបើយើងចង់គេង គឺយើងអាចបិទវាំងននបាន ដើម្បីកុំឲ្យអ្នកដទៃមើលឃើញយើង ដូច្នេះនៅក្នុងរូបភាពនេះ គាត់អត់ទាន់បិទវាំងននទេ ដោយសារតែគាត់អត់ទាន់គេង គឺគាត់ទើបតែរៀបចំគ្រែគេងរបស់គាត់តែប៉ុណ្ណោះ។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ បន្ទាប់ពីគាត់លាតគ្រែគេងរបស់គាត់ហើយ បន្ទាប់ពីគាត់លាតគ្រែគេងរបស់គាត់ហើយ គាត់បានយកខ្នើយនិងភួយមក អញ្ចឹងនៅពេលដែលយើងជិះរថភ្លើងនៅពេលយប់ ហើយយើងយកកៅអីដែលមានគ្រែគេង អញ្ចឹងគេតែងតែឲ្យខ្នើយយើងមួយនិងភួយយើងមួយ សម្រាប់គេងនៅលើគ្រែនោះ ដូច្នេះហើយនៅពេលដែលយើងលាតគ្រែគេង យើងនឹងឃើញខ្នើយ យើងនឹងឃើញភួយ ដែលគេដាក់នៅលើគ្រែ ដូច្នេះប៉ុន្តែមុននឹងពេលគេង យើងត្រូវរលាស់ភួយនោះចេញសិន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ព្រោះថាប្រសិនបើយើងអត់រលាស់ភួយទេ គឺអាចមានសត្វនៅក្នុងភួយនោះ
ឬក៏មានដីនៅក្នុងភួយនោះ អាចធ្វើឲ្យយើងពិបាកគេង ម្យ៉ាងវិញទៀតប្រសិនបើមានសត្វល្អិត
វាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បាន ដោយសារតែវាជិត ឬក៏វាខាំយើង
អញ្ចឹងវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បានដោយសារតែសត្វល្អិត ដូច្នេះមុននឹងយើងដណ្តប់ភួយ
យើងត្រូវតែរលាស់ភួយឲ្យចេញសិន ដើម្បីឲ្យអស់ដី ឬក៏ដើម្បីឲ្យអស់សត្វ
ឬក៏ឲ្យសត្វខ្លាតចេញពីភួយនោះ មុននឹងយើងគេង។

បន្ទាប់មកទៀតរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថា
បន្ទាប់ពីគាត់រៀបចំកន្លែងគេងហើយ បុរសម្នាក់នោះ គាត់ក៏បានគេងទៅលើគ្រែរបស់គាត់
ដោយគាត់គេងកើយលើខ្នើយ ហើយគាត់ដណ្តប់ភួយ ដោយសារតែមានអាកាសធាតុត្រជាក់
ដូច្នេះគាត់ត្រូវដណ្តប់ភួយដើម្បីកុំឲ្យរងា គឺដើម្បីរក្សាកម្តៅនៅក្នុងខ្លួនកុំឲ្យរងា
អញ្ចឹងហើយគាត់ត្រូវដណ្តប់ភួយ បន្ទាប់មកទៀតគាត់បានបិទវាំងននរបស់គាត់
អញ្ចឹងវាំងននបង្អួចដែលមើលទេសភាព គឺយើង បង្អួចដែលមើលទេសភាព គឺមានវាំងននពីរផងដែរ
ដូច្នេះប្រសិនបើយើងអត់ចង់ឲ្យមានពន្លឺព្រះចន្ទជះចូលក្នុងកន្លែងយើងគេងទេ
យើងអាចបិទវាំងននបាន ដើម្បីឲ្យយើងគេងបានងាយស្រួលក្នុងការគេងលក់
អញ្ចឹងនៅក្នុងរូបភាពនេះ បុរសម្នាក់នោះ គាត់អត់បានបិទវាំងននផ្លូវដើរនោះទេ
ព្រោះកន្លែងរបស់គាត់មានវាំងននផ្លូវដើរដែរ ក៏ប៉ុន្តែគាត់អត់បានបិទវាំងននផ្លូវដើរទេ
គឺគាត់គ្រាន់តែបិទវាំងននដែលសម្រាប់មើលទេសភាពតែប៉ុណ្ណោះ
ព្រោះគាត់អត់ចង់ឲ្យមានពន្លឺព្រះចន្ទជះចូលទៅក្នុងកន្លែងគេងរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា បន្ទាប់
ក្រោយពីគាត់គេងយ៉ាងយូរមក ព្រះអាទិត្យក៏ចាប់ផ្តើមរះ អញ្ចឹងបានន័យថាវាជាពេលព្រឹក
ដូច្នេះយើងឃើញនៅក្នុងរូបភាពនេះ យើងឃើញនៅខាងក្រោយបុរសម្នាក់នោះ
យើងឃើញមានព្រះអាទិត្យកំពុងតែរះ អញ្ចឹងជាទូទៅមួយថ្ងៃ គឺមានបួនពេល គឺមានពេលព្រឹក
ពេលថ្ងៃត្រង់ ពេលរសៀល និងពេលយប់ អញ្ចឹងគាត់ជិះរថភ្លើងចាប់ពីពេលថ្ងៃរហូតដល់ពេលយប់
ហើយពេលព្រឹកឡើងគឺគាត់ភ្ញាក់ពីគេងនៅលើរថភ្លើង
អញ្ចឹងយើងឃើញនៅខាងក្រៅគឺជាព្រះអាទិត្យកំពុងរះ ហើយយើងនៅពេលដែលព្រះអាទិត្យរះ
យើងអាចមើលឃើញទេសភាពនៅតាមដងផ្លូវបានយ៉ាងងាយស្រួលនិងយ៉ាងស្រស់ស្អាត
ដោយយើងឃើញបុរសម្នាក់នោះ គាត់បានងើបឡើង ហើយអង្គុយពត់ខ្លួននៅលើគ្រែរបស់គាត់
អញ្ចឹងគាត់បានងើបពីគ្រែគេងនៅលើរថភ្លើងនោះ ប៉ុន្តែគាត់អត់ងើបចេញទេ គឺគាត់អង្គុយនៅលើគ្រែ
ហើយគាត់លើកដៃម្ខាងដាក់ទៅត្រង់ ដៃម្ខាងទៀតខ្ទប់មាត់របស់គាត់កំពុងតែស្ងាប

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់កំពុងតែស្វាបបន្ទាប់មកពីគាត់ក្រោកពីគេង វាហាក់បីដូចជាគាត់មិនទាន់អស់ងងុយ
អញ្ចឹងបានន័យថាគាត់អត់ទាន់អស់ងងុយទេ គឺគាត់នៅងងុយគេងតិចៗ
ប៉ុន្តែដល់ម៉ោងក្រោកពីគេងហើយ ដូច្នេះគាត់ត្រូវតែក្រោក អញ្ចឹងនៅពេលដែលយើងក្រោកពីគេង
ហើយយើងអត់ទាន់អស់ងងុយ គឺយើងតែងតែស្វាប អញ្ចឹងយើងតែងតែពត់ខ្លួន ហើយស្វាប
ដើម្បីឲ្យមានអារម្មណ៍ថាស្រួលខ្លួនក្រោយពីក្រោកពីគេង ជាក់ស្តែងបុរសម្នាក់នេះ
គាត់បានក្រោកពីគេង ហើយស្វាប ដោយយកដៃរបស់គាត់ម្ខាងខ្ទប់មាត់
ដៃម្ខាងទៀតគឺពត់ខ្លួនរបស់គាត់ ដោយយើងឃើញនៅលើគ្រែរបស់គាត់ គឺមានខ្នើយកើយមួយ
និងមានភួយមួយសម្រាប់ដណ្តប់ ប៉ុន្តែដោយសារតែគាត់ងើបពីគេង
ដូច្នេះគាត់អត់ដណ្តប់ភួយទៀតទេ គឺភួយរបស់គាត់គឺនៅលើគ្រែរបស់គាត់ដដែល។

បន្ទាប់មកទៀតរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ បន្ទាប់ពីគាត់ក្រោកពីគេងហើយ
គាត់ក៏បានឡើងអង្គុយ អញ្ចឹងគាត់បានរៀបចំគ្រែរបស់គាត់ឲ្យទៅជាកៅអីអង្គុយវិញ
ដោយសារតែគាត់ឈប់គេងហើយ អញ្ចឹងគាត់ត្រូវរៀបកៅអីរបស់គាត់ឲ្យទៅជាកន្លែងអង្គុយ
ដើម្បីអង្គុយនៅក្បែរបង្អួចមើលទេសភាព ប៉ុន្តែមួយសន្ទុះក្រោយមក
គឺមានការបម្រើអាហារពេលព្រឹកនៅលើរថភ្លើងផងដែរ
អញ្ចឹងជាទូទៅប្រសិនបើយើងជិះរថភ្លើងផ្លូវឆ្ងាយ ជិះច្រើនម៉ោង
គឺគេតែងតែមានបម្រើអាហារនៅលើនោះ ដើម្បីកុំឲ្យអ្នកដំណើរគាត់ឃ្លាន
ព្រោះប្រសិនបើយើងធ្វើដំណើរយូរ គឺអាចធ្វើឲ្យអ្នកដំណើរឃ្លាន អញ្ចឹងនៅលើរថភ្លើង
គេតែងតែរៀបចំជាអាហារសម្រន់ ដើម្បីកុំឲ្យអ្នកដំណើរឃ្លាន ជាក់ស្តែងនៅក្នុងរូបភាពនេះ
គឺអ្នកបម្រើនៅលើរថភ្លើង គាត់បានយកនំ ឬក៏[ហាំប៊ឺហ្គឺរ] ឬក៏សាំងវិចមួយ ហើយនិងកាហ្វេមួយកែវ
មកឲ្យបុរសម្នាក់ដែលពាក់អាវពណ៌លឿងនោះ អញ្ចឹងយើងឃើញបុរសម្នាក់ពាក់អាវពណ៌បៃតង
គាត់កំពុងតែកាន់សាំងវិច ឬក៏កាន់[ហាំប៊ឺហ្គឺរ] ហើយនិងដៃម្ខាងរបស់គាត់ គឺកាន់កែវកាហ្វេមួយ
ដែលកំពុងតែក្តៅ ដែលទាំងអស់នេះគឺជាអាហារពេលព្រឹកសម្រាប់បុរសពាក់អាវលឿងនោះ
អញ្ចឹងនៅលើរថភ្លើងគឺគេបម្រើអាហារពេលព្រឹក ដោយមិនគិតថ្លៃនោះទេ
ដោយសារតែយើងបានទិញសំបុត្ររួចហើយ ដូច្នេះនៅពេលព្រឹកឡើង ដើម្បីកុំឲ្យអ្នកដំណើរឃ្លាន
គឺគេតែងតែបម្រើអាហារពេលព្រឹកទៅដល់អតិថិជនរបស់គេ
ឬក៏បម្រើអាហារពេលព្រឹកទៅដល់អ្នកដំណើរទាំងអស់ដែលជិះនៅរថភ្លើង។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា មួយសន្ទុះក្រោយមក គឺគាត់
រថភ្លើងបានមកដល់ទីក្រុងមួយ អញ្ចឹងបុរសម្នាក់នោះ គាត់បានអង្គុយនៅមាត់បង្អួច
ហើយមុខរបស់គាត់ងាកចេញទៅក្រៅ ដោយគាត់ញញឹមនិងសប្បាយរីករាយ ព្រោះថាបាន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់បានមកដល់ទីក្រុងហើយ អញ្ចឹងអាចជាទីក្រុងកូឡាឡាំពួរនៃប្រទេសម៉ាឡេស៊ី
ដោយសារតែនៅក្នុង នៅក្នុងទេសភាព ដែលនៅក្រៅបង្អួចនេះ យើងឃើញមានអគារតូចធំជាច្រើន
ដែលតម្រៀបគ្នានៅតាមដងផ្លូវ អញ្ចឹងប្រសិនបើនៅទីជនបទ គឺអត់សូវមានអគារធំៗទេ
គឺច្រើនតែមានដើមឈើធំៗ ហើយទេសភាពពណ៌បៃតង
ក៏ប៉ុន្តែនៅទីក្រុងគឺយើងអត់សូវមានដើមឈើទេ ក៏ប៉ុន្តែសម្បូរទៅដោយអគារធំៗ
អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញ នៅខាងក្រៅគឺមានអគារធំៗជាច្រើន និងផ្ទះថ្មីជាច្រើន
ដូច្នេះបានន័យថាគាត់មកដល់ទីក្រុងហើយ ហើយផ្ទៃមេឃគឺស្រឡះ គឺមានពពកស
កំពុងតែរសាត់នៅលើអាកាស គឺអត់មានភ្លៀងទេ អញ្ចឹងអាកាសធាតុល្អ មេឃស្រឡះល្អ
អញ្ចឹងបុរសម្នាក់នោះ គាត់សប្បាយរីករាយយ៉ាងខ្លាំង
ដោយគាត់អង្គុយមើលទេសភាពនៅខាងក្រៅរថភ្លើង អង្គុយមើលទេសភាពនៅតាមដងផ្លូវ
ហើយគាត់បានមកដល់ទីក្រុងហើយ។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា បន្ទាប់ពីមកដល់ទីក្រុង
យើងឃើញរថភ្លើងក៏បានមកដល់ស្ថានីយរថភ្លើងផងដែរ
អញ្ចឹងបានន័យថាគាត់មកដល់ទីក្រុងកូឡាឡាំពួរហើយ
ដូច្នេះរថភ្លើងក៏បានចូលទៅដល់ស្ថានីយរថភ្លើង រួចហើយក៏ឈប់ អញ្ចឹងនៅពេលដែលរថភ្លើងឈប់
គឺរថភ្លើងបានបើកទ្វារឲ្យអ្នកដំណើរចេញ ដោយយើងឃើញនៅក្នុងរូបភាពទី ១៦ នេះ
បុរសដែលពាក់អាវលឿងនោះ គាត់ក៏បានចុះពីលើរថភ្លើង ដោយគាត់ដើរបណ្ដើរ
និងអូសវ៉ាលិសគាត់បណ្ដើរ ដោយវ៉ាលិសគាត់មានកង់ ដូច្នេះគាត់អត់ចាំបាច់យួរនោះទេ
គឺគាត់គ្រាន់តែចាប់កាន់កន្លែងអូសរបស់វ៉ាលិសនោះ ហើយគាត់អូសវ៉ាលិសទៅលើដី
ដោយសារតែវ៉ាលិសមានកង់ ដូច្នេះវាងាយស្រួលក្នុងការអូស
វាងាយស្រួលក្នុងការឲ្យយើងយកតាមខ្លួនធ្វើដំណើរផ្លូវឆ្ងាយ
ដោយយើងមិនចាំបាច់ប្រើកម្លាំងលើកវ៉ាលិសនោះឡើងនោះទេ ដោយគាត់
ដោយយើងគ្រាន់តែអូសវា វានឹងទៅតាមយើងដោយតាមសម្រួល
អញ្ចឹងជាក់ស្ដែងនៅក្នុងរូបភាពនេះ គឺយើងឃើញបុរសម្នាក់ដែលពាក់អាវលឿងនោះ
គាត់អូសវ៉ាលិសគាត់ចេញពីរថភ្លើង ដើម្បីធ្វើដំណើរទៅកាន់គោលដៅរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១៧ នៅក្នុងរូបភាពទី ១៧ យើងឃើញថា
បន្ទាប់ពីគាត់ចេញពីលើរថភ្លើងហើយ បុរសម្នាក់នោះ គាត់ក៏បាននៅក្នុងស្ថានីយរថភ្លើង
ហើយគាត់ក៏បានធ្វើដំណើរចេញពីស្ថានីយរថភ្លើងនោះ ដោយគាត់ដើរបណ្ដើរ
ចេញទៅតាមខ្លោងទ្វារបណ្ដើរ ហើយអូសវ៉ាលិសគាត់បណ្ដើរ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់អូសវ៉ាលិសពណ៌ទឹកក្រូចរបស់គាត់ ចេញទៅខ្លោងទ្វារ ដោយនៅលើខ្លោងទ្វារនោះ
យើងឃើញមានសរសេរអក្សរថា កូឡាឡាំពួរ អញ្ចឹងបានន័យថាវាគឺជាទីក្រុងរបស់ប្រទេសម៉ាឡេស៊ី
អញ្ចឹងគាត់បានមកដល់ទីក្រុងកូឡាឡាំពួរនៃប្រទេសម៉ាឡេស៊ីហើយ
ដោយគាត់ចាកចេញពីទីក្រុងបាងកកនៃប្រទេសថៃ
ហើយធ្វើដំណើរមកកាន់ទីក្រុងកូឡាឡាំពួរនៃប្រទេសម៉ាឡេស៊ី ដោយជិះរថភ្លើងពេលយប់
អញ្ចឹងគាត់ជិះរថភ្លើងពេលយប់ គាត់គេងនៅលើរថភ្លើងផង គាត់អង្គុយផង
ដោយនៅលើរថភ្លើងគឺមានបម្រើអាហារពេលព្រឹកផងដែរ អញ្ចឹងនៅក្នុងស្ថានីយរថភ្លើងនោះ
យើងឃើញមានស្ត្រីម្នាក់ កំពុងតែឈរចាំសាច់ញាតិ អញ្ចឹងគាត់ឈរកាន់វ៉ាលិសរបស់គាត់ដែល
ដោយគាត់ឈរ គាត់អត់ធ្វើដំណើរទៅណាទេ អញ្ចឹងប្រហែលជាគាត់ចាំមិត្តភក្តិ
ឬក៏ចាំបងប្អូនរបស់គាត់ ដើម្បីមកទទួលគាត់ទៅផ្ទះ អញ្ចឹងនៅពេលដែលយើងទៅណា
ឬក៏ទៅកន្លែងឆ្ងាយមានបងប្អូន យើងតែងតែហៅឲ្យបងប្អូនរបស់យើង ឬក៏មិត្តភក្តិរបស់យើង
មកទទួលយើងដើម្បីយកទៅផ្ទះ ព្រោះយើងអត់មានស្គាល់កន្លែងណានោះទេ
ចំណែកឯបុរសម្នាក់នេះ ប្រហែលជាគាត់អត់មានបងប្អូននៅទីនេះទេ
ប្រហែលជាគាត់ជាអ្នកទេសចរណ៍ ដូច្នេះហើយគាត់អត់មានបងប្អូន
អញ្ចឹងគាត់អត់ចាំបងប្អូនគាត់នៅស្ថានីយរថភ្លើងទេ គឺគាត់យួរវ៉ាលិសរបស់គាត់ទៅខាងក្រៅ
ចេញពីស្ថានីយរថភ្លើង ដើម្បីរកកន្លែងសម្រាក ដើម្បីធ្វើដំណើរកម្សាន្តរបស់គាត់
នៅទីក្រុងកូឡាឡាំពួរនៃប្រទេសម៉ាឡេស៊ី។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.